# កម្មវិធីដឹកនាំដោយខ្លួនឯង

ការគាំទ្រ ការផ្តល់អំណាច ជម្រើស

# កម្មវិធី Agency with Choice

កម្មវិធី Agency with Choice ផ្តល់ជូនជម្រើស ដើម្បីសហការជាមួយទីភ្នាក់ងារមួយ។ សម្រាប់បុគ្គលទាំងនោះដែលមានបំណងចង់ចូលរួមការទទួលខុសត្រូវចំពោះការជ្រើសរើសបុគ្គលិកជំនួយរបស់ពួកគេ និងដឹកនាំសកម្មភាពប្រចាំថ្ងៃរបស់ពួកគេនោះ គំរូកម្មវិធី Agency with Choice អាចជាជម្រើសមួយដើម្បីគិតពិចារណា។

បុគ្គលនានាដែលជ្រើសរើសគំរូជំនួយនេះ នឹងមានការបែងចែកថវិកាសម្រាប់ការទិញសេវាកម្ម ដើម្បីបំពេញតម្រូវការរបស់ពួកគេ។ អ្នកចូលរួម/គ្រួសារអាចកំណត់អត្តសញ្ញាណមនុស្សដែលពួកគេមានបំណងចង់ជួលឱ្យបម្រើការងារដោយមានការគាំទ្រពីភ្នាក់ងារមួយ ដើម្បីជួយក្នុងដំណើរការជួលបុគ្គលិកបម្រើការងារ ការគ្រប់គ្រងប្រាក់បៀវត្សរ៍ និងកិច្ចការដែលពាក់ព័ន្ធផ្សេងទៀត។

**កម្មវិធី Agency with Choice Program ផ្តល់ជូនដូចខាងក្រោម៖**

- គំរូសហការងារដែលទីភ្នាក់ងារបម្រើការងារជានិយោជក ដោយបង្កើតជាដៃគូជាមួយបុគ្គលនោះ ដើម្បីជួយបណ្តុះបណ្តាល និងគ្រប់គ្រងបុគ្គលិក។
- ទីភ្នាក់ងារនឹងគាំទ្របុគ្គលម្នាក់ៗដើម្បីសម្ភាសន៍ ជួលបុគ្គលិកបម្រើការងារ និងចរចាអំពីអត្រាប្រាក់ឈ្នួលសម្រាប់បុគ្គលិកនោះ អ្នកចូលរួម/គ្រួសារកំណត់អត្តសញ្ញាណដោយស្របតាមគោលការណ៍បុគ្គលិករបស់ទីភ្នាក់ងារ។
- អ្នកចូលរួម/គ្រួសារមានការទទួលខុសត្រូវចំពោះការត្រួតពិនិត្យប្រចាំថ្ងៃរបស់បុគ្គលិក។
- ទីភ្នាក់ងារនេះទទួលខុសត្រូវលើការបង់ប្រាក់ជូនបុគ្គលិក រួមទាំងការកាត់ទុក ការដាក់ឯកសារ និងការបង់ពន្ធលើប្រាក់ចំណូលសហព័ន្ធនិងរដ្ឋ ការបង់ពន្ធការងារ ព្រមទាំងការផ្តល់ជូនគោលនយោបាយសំណងបុគ្គលិកផងដែរ។
- ភ្នាក់ងារផ្តល់ជូនបុគ្គលនូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ដូច្នេះបុគ្គលម្នាក់ៗដឹងថាការចំណាយកើតមានឡើងតាមផែនការគ្រោងទុក ហើយអាចធ្វើការកែតម្រូវ ប្រសិនបើចាំបាច់។
- ជម្រើសសេវាកម្មនៅក្នុងគំរូកម្មវិធី Agency with Choice រួមមាន៖
    - ការស្វែងរកសេវាកម្ម
    - ការគាំទ្រលំនៅដ្ឋានជាលក្ខណៈបុគ្គល
    - ការគាំទ្រប្រចាំថ្ងៃជាលក្ខណៈបុគ្គល
    - មូលនិធិដែលអាចបត់បែនបាន

## នាយកដ្ឋានសេវាកម្មអភិវឌ្ឍន៍នៃរដ្ឋ MASSACHUSETTS